ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៦៥.......សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់លេខបុគ្គលប្រធានសម្រាប់ឆ្នាំ២០១៥
# របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
... CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក ៦៤ "បន្ទុកបុគ្គលិក", នៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

តារាងឧបសម្ព័ន្ធផ្ទេរទៅបុរេប្រទាន
ថវិកាកម្មវិធីឆ្នាំ២០១៥ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន ផ្ទេរទៅបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ដងបង្វិល ផ្ទេរទៅបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដង | ៦=៣/២ |
| | | | សរុប (I +II) | 825,600,000 | 625,200,000 | 496,367,600 | 128,832,400 | 124,091,900 | 79.4% |
| | | | I.ឥណទានតាមជំពូកដោយមិនគិតបញ្ចូលចំណាយប្រាក់បៀវត្សក្នុងប្រទេស | 357,600,000 | 157,200,000 | 46,700,000 | 110,500,000 | 11,675,000 | 29.7% |
| 60 | | | ការទិញ | 282,100,000 | 100,000,000 | 29,900,000 | 70,100,000 | 7,475,000 | 29.9% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 87,000,000 | 87,000,000 | 26,100,000 | 60,900,000 | 6,525,000 | 30.0% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 4,300,000 | 4,300,000 | 4,300,000 | - | 1,075,000 | 100.0% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 12,800,000 | 12,800,000 | 2,800,000 | 10,000,000 | 700,000 | 21.9% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 69,900,000 | 69,900,000 | 19,000,000 | 50,900,000 | 4,750,000 | 27.2% |
| | 6005 | | សម្ភារៈក្ចការិយាល័យ សម្ភារៈបរិក្ខារ | 120,400,000 | 13,000,000 | 3,800,000 | 9,200,000 | 950,000 | 29.2% |
| | | 60052 | សម្ភារៈ | 10,000,000 | 10,000,000 | 800,000 | 9,200,000 | 200,000 | 0.0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| 61 | | | សេវាកម្ម | 52,000,000 | 52,000,000 | 15,500,000 | 36,500,000 | 3,875,000 | 29.8% |
| | 6105 | | ការថែទាំនិងជួសជុល | 50,000,000 | 50,000,000 | 13,500,000 | 36,500,000 | 3,375,000 | 27.0% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 10,000,000 | 10,000,000 | 2,000,000 | 8,000,000 | 500,000 | 20.0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 17,000,000 | 17,000,000 | 2,500,000 | 14,500,000 | 625,000 | 14.7% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 20,000,000 | 20.000,000 | 6,000,000 | 14,000,000 | 1,500,000 | 30.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| 64 | | | បន្ទុកបុគ្គលិក | 23,500,000 | 5,200,000 | 1,300,000 | 3,900,000 | 325,000 | 25.0% |
| | 6404 | | លាភការនិងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ | 13,500,000 | - | - | - | - | #DIV/0! |
| | | 64043 | បៀវត្សមូលដ្ឋាន បុគ្គលិកអណ្តែត | 13,500,000 | | | - | - | #DIV/0! |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ | 10,000,000 | 5,200,000 | 1,300,000 | 3,900,000 | 325,000 | 25.0% |
| | | 64051 | មន្ត្រីមានជំងឺ | 3,200,000 | 3,200,000 | 800,000 | 2,400,000 | 200,000 | 25.0% |
| | | 64052 | អ្នកសំរាលកូន | 2,800,000 | | | 0 | 0 | #DIV/0! |
| | | 64053 | មរណៈភាព | 2,000,000 | 2,000,000 | 500,000 | 1,500,000 | 125,000 | 25.0% |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព | 2,000,000 | | | 0 | 0 | #DIV/0! |

៤